## គោលបំណងរបស់គំរោង

គោលបំណងរួមរបស់គំរោងគឺ ដើម្បីបង្កើតអោយមានការវិភាគដោយលំអិត លើស្ថានភាពរួមមួយនៃប្រព័ន្ធផលិតកម្មអាហារជលផលជាយក្រុង នៅតំបន់សិក្សាក្នុងទីក្រុងចំនួន ៤ នៃតំបន់អាស៊ីអគ្នេយ៏។ ជាក់លាក់ជាងនេះ គំរោងបានប្រើប្រាស់ វិធីសាស្រ្តជាលក្ខណៈចំណេះដឹងចំរុះ ដោយបែងចែកការងារជា ៣ កញ្ចប់ផ្សេងគ្នា គឺសិក្សាទៅលើកត្តាសេដ្ឋកិច្ចសង្គម សុខភាព/បរិស្ថាន និងប្រព័ន្ធ-ផលិតកម្ម។ ជាដំបូង គំរោងបានធ្វើការវាយតំលៃសហគមន៏ដោយមានការចូលរួម (PCA) និង បន្ទាប់មកធ្វើការអង្កេតជាទំរង់មូលដ្ឋាន (Baseline) និង តាមដាន (Monitoring) សំដៅធ្វើការ អធិប្បាយអំពីតួនាទីរបស់ប្រព័ន្ធផលិតកម្មអាហារនៅតំបន់ជាយក្រុង ចំពោះជីវភាពរស់នៅរបស់អ្នកពាក់ព័ន្ធដំបូង( កសិករ) ដែលក្នុងខណៈនោះដែរ កំនត់នូវ ស្ថានភាពសង្គមនិងភាពងាយរងគ្រោះ ភាពតានតឹងនិងជំលោះខាងផ្នែកបរិស្ថាន ព្រមទាំងប្រព័ន្ធផលិតកម្មផ្សេងគ្នា នៅក្នុងទីក្រុងទាំង ៤ នោះ។ ការសិក្សារបស់គំរោងក៏បានធ្វើការវិភាគទៅលើ ទីផ្សារ និង ក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញនូវលទ្ធផលរកឃើញ របស់គំរោង។ ការអង្កេតទៅលើសុខភាព និងបរិស្ថាននៅក្នុងទីក្រុង ហាណូយ និងភ្នំពេញក៏បានផ្តល់នូវការវាយតំលៃជាលក្ខណៈដំបូង លើគ្រោះថ្នាក់ខាងផ្នែកសុខភាពរបស់អ្នកផលិត និង អ្នកប្រើប្រាស់ ដែលមានទំនាក់ទំនងជាមួយ ការប្រើប្រាស់ទឹកសំណល់ និង ការកែច្នៃប្រើប្រាស់ឡើងវិញនៅក្នុងប្រព័ន្ធនេះ។

គោលបំណងនៅចុងបញ្ចប់ គឺជំរុញអោយមានអន្តរអំពើ ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងឡាយមកពីថ្នាក់ក្រុង ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដោយក្នុងនោះដែរដាក់បញ្ចូលគំនិតយោបល់របស់គេ ទៅក្នុងដំណើរការស្រាវជ្រាវ និងពង្រីកទស្សនៈវិស័យលើយុទ្ធសាស្រ្តគ្រប់គ្រង និងធ្វើផែនការនៅថ្ងៃអនាគតរួចធ្វើការផ្សព្វផ្សាយលទ្ធផលទាំងនោះអោយបានទូលំទូលាយក្នុងទំរង់សមស្របដើម្បីលើកកំពស់ចំណេះ-ដឹង និងផ្តល់ជាពតិមានដល់អ្នកធ្វើគោលនយោបាយនិងធ្វើផែនការទីក្រុង នូវផលប្រយោជន៏ និង ឧបសគ្គនាពេលបច្ចុប្បន្ននិងអនាគតក្នុងការដាំដុះដំណាំបន្លែជលផល និង ការចិញ្ចឹមត្រី នៅក្នុង និង ជុំវិញទីក្រុងធំៗ នៃតំបន់អាស៊ីអគ្នេយ៏។